# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៥៥...សសរ....

## សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ ហៅកាត់ថា " ការិយាល័យសន្តិសុខថ្នាក់កណ្តាល "**

ឞឞឞ✧ឍឍឍ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

<u>ប្រការ ១</u> : ត្រូវបានបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ ហៅកាត់ថា " **ការិយាល័យសន្តិសុខថ្នាក់កណ្តាល** " ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម ទៀ បាញ់ | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | **អនុប្រធាន** |
| ៣-ឯកឧត្តម គាត ឈន់ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | **សមាជិក** |
| ៤-ឯកឧត្តម យូ ហុកគ្រី | ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | **សមាជិក** |
| ៥-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន | សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ | **សមាជិក** |
| ៦-ឯកឧត្តម ឆា ចំរើន | ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកការងារការពារសន្តិសុខសណ្តាប់ធ្នាប់សំរាប់ការបោះឆ្នោត | **សមាជិក** |
| ៧-ឯកឧត្តម កែ គឹមយ៉ាន | អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ | **សមាជិក** |

៨-ឯកឧត្តម ឃុន ឡុងឌី អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ **សមាជិក**

៩-ឯកឧត្តម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

<u>ប្រការ ២</u> : ការិយាល័យសន្តិសុខថ្នាក់កណ្តាលមានភារកិច្ច ៖

- សហការ សំរបសំរួលជាមួយគណៈកម្មាធិការផ្នែកសន្តិសុខ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- ចាត់តាំងកំលាំងជំនាញមានសមត្ថកិច្ច ចុះសហការអោយបានជិតស្និទ្ធជាមួយយន្តការផ្នែកសន្តិសុខតាមឋានានុក្រម ដើម្បីធានាអោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។
- ផ្សព្វផ្សាយពត៌មាន គោលការណ៍ វិធានការសន្តិសុខ ជូនទៅការិយាល័យសន្តិសុខថ្នាក់ក្រោម ។
- ប្រមូលផ្តុំពត៌មាន ពាក្យបណ្តឹង ទាក់ទិននឹងសន្តិសុខពីការិយាល័យសន្តិសុខខេត្ត ក្រុង ដើម្បីពិនិត្យ ដោះស្រាយ និងបញ្ជាណែនាំ ។
- ប្រមូលផ្តុំចាត់ចែងកំលាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ដោយប្រើប្រាស់សំភារៈឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់អង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈអោយមានប្រសិទ្ធភាពខ្ពស់ដល់ដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

<u>ប្រការ ៣</u> : ការិយាល័យសន្តិសុខថ្នាក់កណ្តាលមានសិទ្ធិបង្កើតលេខាធិការដ្ឋាន ដើម្បីជាជំនួយក្នុងការតាមដាន ដឹកនាំ បញ្ជា និងមានសិទ្ធិប្រើប្រាស់ត្រានិងថវិការបស់គណៈរដ្ឋមន្ត្រី ។

<u>ប្រការ ៤</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**កន្លែងទទួល :**</u>

*-ទីស្តីការក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-ដូចប្រការ៤*
*-ឯកសារ-កាលប្បវត្តិ*